មជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
Cambodian Center for Independent Media

លេខ : ................

# សេចក្តីប្រកាសព័ត៌មាន

## ការផ្សព្វផ្សាយរបាយការណ៍ "បញ្ហាប្រឈមនៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យឆ្នាំ ២០១៧"

ការបង្ក្រាបរបស់រដ្ឋាភិបាលទៅលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅឆមាសទីពីរនៃឆ្នាំ២០១៧ បានបង្ហាញពីភាពងាយរងគ្រោះរបស់ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។ ទោះជាយ៉ាងណាក៏ដោយ ភាពតានតឹងរបស់រដ្ឋាភិបាលនៅក្នុងចន្លោះខែសីហានិងកញ្ញាឆ្នាំ២០១៧ មិនបានបញ្ជាក់ច្បាស់អំពីបញ្ហាប្រឈមទាំងអស់ដែលប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅ កម្ពុជាកំពុងប្រឈមឡើយ។ ការគំរាមកំហែងផ្នែកច្បាប់ ភាពលំបាកក្នុងការរាយការណ៍អំពីបញ្ហារសើប និងប្រាក់ខែ តិចគឺជាបញ្ហាប្រឈមមួយចំនួនដែលអ្នកកាសែតឯករាជ្យនិង ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយនៅ កម្ពុជាកំពុងជួបប្រទះ។ ដោយមាន ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសពីសហភាពអឺរ៉ុប និងការិយាល័យប្រចាំកម្ពុជានៃ អង្គការ DanChurchAid មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ(CCIM) នឹងធ្វើការផ្សព្វផ្សាយរបាយការណ៍ស្តីអំពី **"បញ្ហាប្រឈមនៃ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជាឆ្នាំ២០១៧"** នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដែលនឹងប្រព្រឹត្តទៅ **នៅព្រឹកថ្ងៃពុធ ទី២១ ខែកុម្ភៈ ឆ្នាំ ២០១៨ នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។** កម្មវិធីនេះ នឹងមានការអញ្ជើញចូលរួមដោយ ឯកឧត្តម **មាស សុភ័ណ្ឌ** អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន និងឯកឧត្តម **George Edgar** ឯកអគ្គរដ្ឋទូត សហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការចូលរួមពីសំណាក់ អ្នកពាក់ព័ន្ធផ្សេងៗទៀត។ នៅក្នុងឱកាសនេះ CCIM មានកិត្តិយសអញ្ជើញតំណាងម្ចាស់ជំនួយ អង្គការដៃគូ តំណាងអង្គការសង្គមស៊ីវិល ស្ថាប័នសារព័ត៌មាន អ្នកសារ ព័ត៌មាន និងអ្នកពាក់ព័ន្ធដទៃជាច្រើនទៀតប្រមាណ ៥០នាក់។ ខណៈពេល ដែលបញ្ហាប្រឈម នៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជាឆ្នាំ ២០១៧ បានផ្តល់នូវលទ្ធផលស្រាវជ្រាវស៊ីជម្រៅ និងទាន់ពេលវេលា ដោយសារតែការបង្រួមសេរីភាពខាងសារព័ត៌មាន។ CCIM សង្ឃឹមថារបាយការណ៍នេះនឹង ផ្តល់អត្ថប្រយោជន៍ដ៏ធំធេងសម្រាប់អ្នក ដែលធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ សម្រាប់អ្នកស្រាវជ្រាវ និងសម្រាប់ ប្រជាជនកម្ពុជាទាំងមូលផងដែរ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង លោក សេក សុផល ដែលជាមន្ត្រីទំនាក់ទំនង និងតស៊ូមតិ នៃមជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ តាមរយៈលេខទូរស័ព្ទ ០៦០ ៤១១ ៨៨៨។

ផ្ទះលេខ១៤A ផ្លូវ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ភ្នំពេញ, ទូរស័ព្ទលេខ៖ ០២៣ ៧២៦ ៨៤២ / ០២៣ ៧២៦ ៨៤៧ ទូរសារ៖ ០២៣ ៧២៦ ៨៤៥
House No14A Street 392, Sangkat Beoung Keng Kang I, Khan Chamkamon, Phnom Penh; Tel : 023 726 842 / 023 726 847 / 023 726 847 / 060 50 50 50;
Fax : 023 726 845, Hotline : 060 50 50 50 / 092 921 902 E-mail : info@ccimcambodia.org Website: www.ccimcambodia.org